**Declassified to Public**
**12 June 2020**



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**
**Royaume du Cambodge**
**Nation Religion Roi**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

---

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

| |
|---|
| **ឯកសារបកប្រែ** |
| **TRANSLATION/TRADUCTION** |
| ថ្ងៃ ខែ ឆ្នាំ (Date): 25-Jan-2017, 09:40 |
| CMS/CFO: Ly Bunloung |

**សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក -ក.ស.ច.ស**

ចំពោះមុខ ៖ សហចៅក្រមស៊ើបអង្កេត
កាលបរិច្ឆេទ ៖ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦
ភាសា ៖ អង់គ្លេស [ភាសាដើម]
ចំណាត់ថ្នាក់ឯកសារ ៖ **សម្ងាត់**

---

# ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បញ្ចូលឯកសារនៃសំណុំរឿង ០០៤ (D193/84) និងសំណើបន្ទាន់សុំឲ្យពិចារណាឡើងវិញលើអនុសាសន៍ដែលបានភ្ជាប់ទៅនឹងការដាក់បញ្ចូលកំណត់ហេតុនៃសំណុំរឿង០០៤ (D193/95)

---

**ផ្ញើជូន៖**

**អង្គជំនុំជម្រះសាលាដំបូង**

**សហព្រះរាជអាជ្ញា៖**
ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី អោ អាន**
មុំ លុជ្ស
Richard ROGERS
Göran SLUITER

**មេធាវីការពារក្តី យឹម ទិត្យ**
សូ ម៉ូស្សេនី
Suzana TOMANOVIĆ

**មេធាវីតំណាង**
**ដើមបណ្តឹងរដ្ឋប្បវេណី៖**
ជេត វណ្ណលី
ហុង គឹមសួន
គឹម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ីន សូវ៉ន
ទី ស្រ៊ីនណា
វ៉ែន ពៅ
Linda BEHNKE

Laure DESFORGES
Herve DIAKIESE
Ferdinand DJAMMEN NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Christine MARTINEAU
Bernabe NEKUI
Lyma NGUYEN
Beini Ye

## I- ប្រវត្តិនីតិវិធី និងសារណា

1. ករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") នៅក្នុងសំណុំរឿងនេះ ត្រូវបានចុះកំណត់ហេតុនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣, ថ្ងៃទី ៥ ខែ មេសា និង ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៤។

2. នៅថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៤ លោកចៅក្រម Mark Harmon បានចេញ*ដីកាសម្រេចសំណើជាបន្ទាន់របស់សហព្រះរាជអាជ្ញាសុំដាក់នូវកំណត់ហេតុស្តាប់ចម្លើយសាក្សីនៃសំណុំរឿង ០០៤ ដែលទាក់ទងនឹងវគ្គទី១នៃការជំនុំជម្រះក្តីនៅក្នុងសំណុំរឿង០០២/០២*[1]។ យើងសូមដាក់បញ្ចូលកថាខណ្ឌ ១ ដល់៧ នៃដីកាសម្រេចនោះដោយធ្វើការលើកយោង។

3. នៅថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១៥ យើងបានចេញ*អនុស្សរណៈពីសហចៅក្រមអន្តរជាតិជូនអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល ទាក់ទងនឹងការដាក់បង្ហាញឯកសារពីសំណុំរឿង០០៣ និង០០៤ ទៅក្នុងសំណុំរឿង០០២* ។ ក្នុងអនុស្សរណៈនោះ យើងបានកំណត់លក្ខខណ្ឌ និងទម្រង់នៃការដាក់បង្ហាញឯកសារ[2]។

4. នៅថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") បានស្នើសុំការអនុញ្ញាតដើម្បីដាក់បង្ហាញឯកសារចំនួន ៣៤ ដែលទាក់ទងទៅនឹងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ ("សំណើ D193/84")[3]។ មានតែក្រុមមេធាវីការពារក្តី យឹម ទិត្យ ប៉ុណ្ណោះដែលជូន

---

[1] សំណុំរឿងលេខ 004-D193/4, *ដីកាសម្រេចសំណើជាបន្ទាន់របស់សហព្រះរាជអាជ្ញាសុំដាក់នូវកំណត់ហេតុស្តាប់ចម្លើយសាក្សីនៃសំណុំរឿង ០០៤ ដែលទាក់ទងនឹងវគ្គទី១នៃការជំនុំជម្រះក្តីនៅក្នុងសំណុំរឿង០០២/០២* ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៤។

[2] សំណុំរឿងលេខ 004-D273, *អនុស្សរណៈពីសហចៅក្រមអន្តរជាតិជូនអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលទាក់ទងនឹង "ការដាក់បង្ហាញឯកសារពីសំណុំរឿង០០៣ និង០០៤ ទៅក្នុងសំណុំរឿង០០២"* ថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១៥។

[3] សំណុំរឿងលេខ 004-D193/84, *សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញឯកសារភ្ជាប់ទៅនឹងឯកសារដែលបានដាក់បង្ហាញទៅក្នុងសំណុំរឿង០០២* ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៦ កថាខណ្ឌ ១។

ដំណឹងដល់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ តាមរយៈអ៊ីម៉ែលថា ពួកគាត់ពុំមានបំណងធ្វើការឆ្លើយតបទេ ហើយក៏ពុំមានក្រុមមេធាវីការពារក្តីណាបានដាក់ចម្លើយតបដែរ។

5. នៅថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៦ ស.ព.អ បានដាក់សំណើជាបន្ទាន់ដើម្បីឲ្យកែប្រែលក្ខខណ្ឌពីដីកាសម្រេច D193/63 លើកំណត់ហេតុស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួនពីររូបក្នុងសំណុំរឿង០០៤ ដែលបានដាក់បង្ហាញនាពេលកន្លងមក។ ដើមបណ្តឹងរដ្ឋប្បវេណីចំនួនពីររូបនោះគ្រោងនឹងមកផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង០០២/០២ (“សំណុំសុំពិចារណាឡើងវិញ”)[4]។ ដោយសារភាពបន្ទាន់ដោយសារតែការផ្តល់សក្ខីកម្មរបស់ពួកគេដែលបានគ្រោងនោះ ស.ព.អ ស្នើឲ្យក្រុមមេធាវីការពារក្តីធ្វើការឆ្លើយតបតាមរយៈអ៊ីម៉ែល។ ក្រុមមេធាវីការពារក្តី អ៊ុម ចែម និង យឹម ទីត្យ បានឆ្លើយតបតាមអ៊ីម៉ែល ដោយលើកឡើងថា ពួកគាត់ពុំមានបំណងធ្វើការឆ្លើយតបឡើយ។ អ៊ីម៉ែលពីក្រុមមេធាវីការពារក្តីតបទៅនឹងសំណើទាំងពីរនេះ ត្រូវបានភ្ជាប់ជាមួយនៅក្នុងឧបសម្ព័ន្ធ ក។

6. នៅថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានឆ្លើយតប តាមរយៈអ៊ីម៉ែល ដែលជាការជួយដល់ការគ្រប់គ្រងសវនាការប្រកបដោយប្រសិទ្ធភាព ថា លក្ខខណ្ឌដែលតម្រូវឲ្យប្រើប្រាស់របស្សនាម និងការលើកឡើងដទៃទៀត ដែលត្រូវបានធ្វើ ដើម្បីជៀសវាងការបង្ហាញអត្តសញ្ញាណបុគ្គលម្នាក់ៗ នឹងត្រូវកែប្រែនៅក្នុងដីកាសម្រេចជាលាយលក្ខណ៍អក្សរ ដើម្បីឲ្យអនុវត្តតាម និងអនុញ្ញាតឲ្យប្រើប្រាស់អ៊ីម៉ែលដើម្បីជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង និងភាគីក្នុងសំណុំរឿង ០០២/០២[5]។ អ៊ីម៉ែលនេះត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធ ខ។

7. នៅថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានធ្វើលិខិតជូនសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដោយសាកសួរថាតើលក្ខខណ្ឌដែលបានកំណត់សម្រាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយរូប មានភាពចាំបាច់ដែរឬទេ ដោយពិចារណាលើការលើកឡើងរបស់ ស.ព.អ ក្នុងពេលសវនាការថា បុគ្គលនោះបានផ្តល់សក្ខីកម្មរួចហើយនៅក្នុងសំណុំរឿង ០០២/០១ កំណត់ត្រា

---

[4] សំណុំរឿងលេខ 004-D193/95, *សំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឲ្យពិចារណាឡើងវិញលើអនុសាសន៍ដែលបានភ្ជាប់ទៅនឹងការដាក់បង្ហាញកំណត់ហេតុនៃសំណុំរឿង០០៤* ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៦។

[5] *ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង០០៤ (D193/84) និងសំណើបន្ទាន់សុំឲ្យពិចារណាឡើងវិញលើអនុសាសន៍ដែលបានភ្ជាប់ទៅនឹងការដាក់បង្ហាញកំណត់ហេតុនៃសំណុំរឿង ០០៤ (D193/95)*

របស់បុគ្គលនោះត្រូវបានផ្សព្វផ្សាយជាសាធារណៈ ហើយដើមបណ្តឹងរដ្ឋប្បវេណីខ្លួនឯងពុំបានជំទាស់ទៅនឹងការផ្តល់សក្ខីកម្មនៅសវនាការជាសាធារណៈឡើយ[6]។ ដូចបានឆ្លើយតបនាពេលកន្លងមក ស.ច.ស.អ បានឆ្លើយតបថា លក្ខខណ្ឌចំពោះការបង្ហាញអត្តសញ្ញាណរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះ អាចធ្វើការកែប្រែ[7]។ អ៊ីម៉ែលទាំងនេះត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធ គ។

## II- ពិភាក្សា

8. ទាក់ទងនឹងសំណើ D193/84 ឯកសារដែលបានស្នើឡើងចំនួន ៣៤ នៅក្នុងសំណើនេះ គឺកំណត់ហេតុស្តាប់ចម្លើយចំនួន ៣ របាយការណ៍ស្តីពីការអនុវត្តកិច្ចស៊ើបសួរ និងឯកសារភ្ជាប់ចំនួន ២៨ ដែលជាឯកសារសំខាន់ចំពោះរបាយការណ៍មួយដែលសរសេរដោយ Rochelle Braaf ស្តីពីអំពើហិង្សាផ្លូវភេទ ដែលត្រូវបានទទួលយកជាភស្តុតាងក្នុងសំណុំរឿង ០០២[8]។ ឯកសារទាំង ៣៤ ដែលបានស្នើឡើង ជាប់ទាក់ទង *ជាបឋម* ទៅនឹងសំណុំរឿង ០០២។ ឯកសារទាំងនេះត្រូវបានស្នើសុំឱ្យយកជាភស្តុតាង ហើយការដាក់បង្ហាញឯកសារទាំងនេះនឹងមិនប៉ះពាល់ទៅដល់សុចរិតភាព និងភាពសម្ងាត់នៃកិច្ចស៊ើបសួរឡើយ។ ចំពោះភស្តុតាងរបស់ពួកគេដែលទាក់ទងនឹងកិច្ចស៊ើបសួរដែលកំពុងធ្វើក្នុងសំណុំរឿង ០០៤ នោះ សាក្សីចំនួន ៣ រូប អាចត្រូវបានចាត់ថ្នាក់ជាសាក្សីប្រភេទ ក។ ឯកសារដែលភ្ជាប់ទៅនឹងរបាយការណ៍របស់ Rochelle Braaf ដែលមាននៅក្នុងសំណុំរឿង ០០២ រួចហើយនោះ ផ្ទុកព័ត៌មានដែលបានផ្សព្វផ្សាយជាសាធារណៈ តាមរយៈប្រភេទផ្សេងទៀត ដូច្នេះ ពុំចាំបាច់ដាក់កម្រិតណាមួយលើការប្រើប្រាស់ឯកសារនេះក្នុងសំណុំរឿង ០០២ ឡើយ។

---

[6] អ៊ីម៉ែលពីអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៦ ដោយដកស្រង់ប្រតិចារិក ថ្ងៃទី២៥ ខែ សីហា ឆ្នាំ ២០១៦ ទំព័រ ៤៨-៥១។

[7] អ៊ីម៉ែលពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៦។ សូមមើលផងដែរ សំណុំរឿងលេខ 004/D193/94 *ដីកាសម្រេចរួមលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញឯកសារនៃសំណុំរឿង០០៤ ទៅក្នុងសំណុំរឿង០០២ (D193/92 & D193/93)* ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ កថាខណ្ឌ ៨។

[8] សំណើ D193/84 កថាខណ្ឌ ១

9. ទាក់ទងនឹងសំណើសុំពិចារណាឡើងវិញ យើងកត់សម្គាល់ថា ព័ត៌មានអំពីភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីពីររូប ដែលកន្លងមកមាននៅក្នុងសំណុំរឿង០០២ មិនត្រូវបានដាក់នៅក្នុងសំណើដើមដើម្បីដាក់បង្ហាញឯកសារឡើយ (D193/38)។ ដូច្នេះ ដីកាសម្រេចដែលអនុញ្ញាតការដាក់បង្ហាញ និងការប្រើប្រាស់ ដាក់លក្ខខណ្ឌដើម្បីការពារសុចរិតភាពនៃភស្តុតាង ដែលលេចឡើងនៅក្នុងសំណុំរឿង០០៤ ជាប្រភេទ ក (D193/61) [9]។ ដូចបានបញ្ជាក់ហើយនៅក្នុងចម្លើយតបតាមរយៈអ៊ីម៉ែល យើងជឿជាក់ថា ព័ត៌មាននេះលុបបំបាត់ភាពចាំបាច់ក្នុងការប្រើប្រាស់រហស្សនាម ឬវិធានការផ្សេងទៀត ដើម្បីរក្សាការសម្ងាត់ចំពោះអត្តសញ្ញាណនៃបុគ្គលទាំងនេះ។

10. ស្រដៀងគ្នានេះដែរ ដូចបានបញ្ជាក់មកយើងតាមរយៈអ៊ីម៉ែល ព័ត៌មានដែល ស.ព.អ បានផ្តល់ដល់អង្គជំនុំជម្រះសាលាដំបូងក្នុងពេលសវនាការ លុបបំបាត់ភាពចាំបាច់ក្នុងការប្រើប្រាស់រហស្សនាម ឬវិធានការផ្សេងទៀត ដើម្បីរក្សាការសម្ងាត់ចំពោះអត្តសញ្ញាណរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានផ្តល់សក្ខីកម្មកាលពីថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ឡើយ។

11. ស.ព.អ បានដាក់សំណើផ្ទាល់មាត់នៅក្នុងសវនាការជាសាធារណៈនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដែលបានរិះគន់ទៅលើលក្ខខណ្ឌដើមនៃការដាក់បង្ហាញភស្តុតាង ដោយពុំបានលើកឡើងអំពីព័ត៌មានពាក់ព័ន្ធ ដែល ស.ព.អ ទទួលបាន និងអាចទទួលបាននៅពេលដាក់សំណើដំបូងឡើយ។ ដូច្នេះ ពុំចាំបាច់ធ្វើការឆ្លើយឆ្លងតាមអ៊ីម៉ែលភ្លាមៗ និងជាបន្ទាន់ ដែលភាគីទាំងអស់ក្នុងសំណុំរឿង០០៣ និង០០៤ ត្រូវឆ្លើយតប ដើម្បីគាំទ្រដល់កាលវិភាគនៃកិច្ចដំណើរការនីតិវិធីសវនាការឡើយ។ ការធ្វើបែបនេះបណ្តាលឲ្យការិយាល័យរបស់យើង និងអ្នកផ្សេងទៀត ត្រូវប្រើប្រាស់ពេលវេលា និងធនធានដោយពុំមានមានសមាមាត្រ និងមិនអាចចៀសផុត។

12. ដីកាសម្រេចនេះត្រូវបានដាក់ជាភាសាអង់គ្លេស និងដាក់ជាភាសាខ្មែរតាមក្រោយ ដោយសារតែភាពបន្ទាន់នៃបញ្ហានេះ និងធនធានផ្នែកបកប្រែភាសាមានកម្រិត។

**ផ្អែកលើសំអាងហេតុខាងលើ យើង៖**

---

[9] សំណើសុំពិចារណាឡើងវិញ ឧបសម្ព័ន្ធ ក។

13. **អនុញ្ញាត**ឲ្យដាក់បង្ហាញឯកសារចំនួន ៣៤ នៅក្នុង**ឧបសម្ព័ន្ធ ឃ** ជូនអង្គជំនុំជម្រះសាលាដំបូង និងភាគីក្នុងសំណុំរឿង០០២/០២។ យោងទៅលើលក្ខណៈសម្ងាត់ និងភាពរសើបនៃកិច្ចស៊ើបសួរដែលកំពុងអនុវត្តក្នុងសំណុំរឿង០០៤ ឯកសារទាំងនេះត្រូវបានអនុញ្ញាតឲ្យដាក់បង្ហាញ ដូចលើកឡើងនៅក្នុង**ឧបសម្ព័ន្ធ ឃ** ក្នុងទម្រង់ និងលក្ខខណ្ឌ ដូចខាងក្រោម៖

(ក) ឯកសារទាំងអស់ដែលបានពីសំណុំរឿង០០៤ ត្រូវចាត់ទុកថាជាឯកសារសម្ងាត់។

(ខ) ក្នុងករណីដែលឯកសារដែលផ្តល់ឲ្យ អនុលោមតាមដីកាសម្រេចនេះ ត្រូវបានទទួលយកជាភស្តុតាងក្នុងសំណុំរឿង ០០២/០២ ឯកសារនោះនឹងត្រូវដាក់ចំណាត់ប្រភេទជាឯកសារសម្ងាត់។

(គ) ក្នុងករណីសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណី ដែលឯកសាររបស់ខ្លួនត្រូវបានអនុញ្ញាតឲ្យដាក់បង្ហាញ ត្រូវបានកោះឲ្យមកផ្តល់សក្ខីកម្ម ពួកគាត់អាចផ្តល់សក្ខីកម្មក្នុងសវនាការជាសាធារណៈ ប៉ុន្តែ ឈ្មោះ និងអត្តសញ្ញាណរបស់ពួកគាត់ ត្រូវរក្សាការសម្ងាត់ លើកលែងតែ Rochelle Braaf ដែលជាអ្នកស្រាវជ្រាវឯករាជ្យ។

(ឃ) មិនត្រូវផ្សព្វផ្សាយឯកសារដែលផ្តល់ឲ្យ យោងតាមដីកាសម្រេចនេះ ដល់បុគ្គលណាឡើយ ក្រៅពីបុគ្គលដែលបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងដីកាសម្រេចនេះ។

(ង) មិនត្រូវផ្សព្វផ្សាយឯកសារដែលបានផ្តល់ឲ្យ យោងតាមដីកាសម្រេចនេះ ទៅសាធារណជន លើសពីភស្តុតាងដែលបានបង្ហាញនៅក្នុងសវនាការសាធារណៈ ក្នុងទម្រង់ណាមួយ ឬតាមប្រព័ន្ធផ្សព្វផ្សាយណាមួយឡើយ។

(ច) ភាគី ឬ ក្រុមមេធាវីការពារក្តីណាមួយ ឬបុគ្គលផ្សេងទៀត ដែលអាន ដកស្រង់ ឬប្រើប្រាស់ឯកសារណាមួយដែលត្រូវបានដាក់បង្ហាញ ត្រូវកំណត់អត្តសញ្ញាណសាក្សី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈតែរហស្សនាមរបស់ពួកគេក្នុងសំណុំរឿង០០២ តែប៉ុណ្ណោះ និងប្រើប្រាស់សេចក្តីពិពណ៌នា ដោយពិចារណាឲ្យបានសមស្រប ដើម្បីជៀសវាងការកំណត់អត្តសញ្ញាណរបស់សាក្សីតាមរយៈព័ត៌មានផ្សេងទៀត។

(ឆ) ឯកសារដែលបានដាក់បង្ហាញ ត្រូវផ្តល់ជូនក្រុមមេធាវីការពារក្តីនៃជនជាប់ចោទទាំងពីរ មេធាវីប្រចាំការការពារក្តី ខៀវ សំផន (“មេធាវីប្រចាំការ”) និងសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈឯកសារចម្លងអេឡិចត្រូនិក។

(ជ) ក្រុមមេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ត្រូវដាក់បង្ហាញឯកសារដែលបានផ្តល់ឲ្យ អនុលោមតាមដីកាសម្រេចនេះ ទៅដល់តែសមាជិកនៃក្រុមរបស់ខ្លួនដែលបានកំណត់ជាផ្លូវការ អនុលោមតាមវិធាន ២២ (៥) និងវិធាន ១២ ស្ទួនពីរ (៤) និងកម្មសិក្សាការីដែលត្រូវបានតែងតាំងជាផ្លូវការប៉ុណ្ណោះ។

(ឈ) ក្រុមមេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី មិនត្រូវបានអនុញ្ញាតឲ្យបោះពុម្ព ផលិតឡើងវិញ ថតចម្លង ស្កេន ឬចម្លងឲ្យដូចដើម នូវឯកសារដើមដែលខ្លួនបានទទួល ក្រៅពីការប្រើប្រាស់ផ្ទៃក្នុងដោយសមាជិកក្រុមរបស់ខ្លួន ដែលទទួលបានការណែនាំ ឬត្រូវបានអនុញ្ញាតឲ្យចូលមើលឯកសារសម្ងាត់ឡើយ។

(ញ) ក្រុមមេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ត្រូវរក្សាកំណត់ត្រាជាលាយលក្ខណ៍អក្សរ ក្នុងលក្ខណៈមួយដែលអនុញ្ញាតឲ្យបោះពុម្ព ផលិតឡើងវិញ ថតចម្លង ស្កេន ឬចម្លងឲ្យដូចឯកសារដើម សម្រាប់ការប្រើប្រាស់ផ្ទៃក្នុង និង

(ដ) ប្រសិនបើសមាជិកណាម្នាក់នៃភាគី ឬអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២ ដឹងអំពីឯកសារដែលត្រូវបានដាក់បង្ហាញ ដែលមិនត្រូវបានអនុញ្ញាត គាត់ត្រូវចាត់វិធានការជាបន្ទាន់ ដើម្បីទទួលបានឯកសារនោះ និងប្រគល់វាទៅឲ្យសហចៅក្រមស៊ើបអង្កេត និង

(ឋ) ប្រសិនបើសមាជិកណាម្នាក់នៃភាគី ឬអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២ ដឹងអំពីការបំពានលើលក្ខខណ្ឌ និងការដាក់កម្រិតទាំងនេះ គាត់ត្រូវរាយការណ៍ជាបន្ទាន់ទៅសហចៅក្រមស៊ើបអង្កេត។

14. **បញ្ជាក់ថា** សម្រាប់គោលបំណងនៃដីកាសម្រេចនេះ "សាធារណៈ" មានន័យថា និងរួមបញ្ចូលទាំងបុគ្គលទាំងអស់ រដ្ឋាភិបាល អង្គការ ស្ថាប័ន ក្មួនក្តី សមាគម និងក្រុមនានា ក្រៅពីចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង បុគ្គលិកផ្នែកគ្រប់គ្រងតុលាការ សហព្រះរាជអាជ្ញា និងតំណាងរបស់គាត់ ជនជាប់ចោទ បុគ្គលិកដែលបានកំណត់អនុលោមទៅតាមវិធាន២២ (៥) និង១២ ស្ទួនពីរ (៤) ដែលទទួលបានការអនុញ្ញាតពីក្រុមមេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ឲ្យចូលពិនិត្យមើលឯកសារសម្ងាត់។ "សាធារណៈ" ក៏រួមបញ្ចូល ដោយគ្មានការកំណត់ សមាជិកគ្រួសារ មិត្តភ័ក្រ្ត និងអ្នកពាក់ព័ន្ធរបស់ជនជាប់ចោទ ជនជាប់ចោទ ក្រុម

មេធាវីការពារក្តី និងសមាជិកនៃបុគ្គលិកក្នុងសំណុំរឿងផ្សេងទៀត ឬកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ប្រព័ន្ធផ្សព្វផ្សាយ និងអ្នកសារព័ត៌មាន។

**15.** **កែប្រែ**លក្ខខណ្ឌនៅក្នុងកថាខណ្ឌ ៣២ (ឃ) និង (៣២) (ង) ក្នុងដីកាសម្រេច D193/61 ទាក់ទងនឹង ជា ឌៀប ប៉ែន សុចាន់ និង យស់ ផល។

**16.** **បញ្ជាក់**ថា លក្ខខណ្ឌ និងការដាក់កម្រិតខាងលើ ត្រូវរក្សាដដែល រហូតដល់លក្ខខណ្ឌ និងការដាក់កម្រិតទាំងនោះ ត្រូវបានកែប្រែ តាមរយៈដីកាសម្រេចដាក់លាក់មួយ ដោយសហចៅក្រមស៊ើបអង្កេត ឬ ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ ត្រូវបានចេញ និង

**17.** **ស្នើឱ្យ**អង្គជំនុំជម្រះសាលាដំបូង ធានាថា ភាគីទាំងអស់អនុវត្តតាមដីកាសម្រេចនេះ។

ភ្នំពេញ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦

**ចៅក្រម Michael Bohlander**

**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

**International Co- Investigating Judge**

**Co-juge d'instruction International**